# ជនរងគ្រោះ ដោយសារទឹកអាស៊ីត មាន ៣១៥ នាក់ រហូតមកទល់ពេលនេះ

Friday, 08 July 2011 16:00 ដោយ ៖ សុក្រ វិច្ឆិកា

http://dap-news.com/typography/the-news/24806-2011-07-08-09-03-54.html

**ភ្នំពេញ ៖** របាយការណ៍ពីអង្គការជួយ ជនរងគ្រោះកម្ពុជា ដោយសារទឹកអាស៊ីត ហៅកាត់ថា CASC បានកត់ត្រាទុកថា រយៈពេល ២០ ឆ្នាំចុងក្រោយមកនេះ អ្នក រងគ្រោះដោយសារទឹកអាស៊ីត នៅប្រទេសកម្ពុជា មានចំនួន ៣១៥នាក់ក្នុងនោះ ៥២ ភាគរយជាស្ត្រី និង៤៨ភាគរយ ជាបុរស ស្ថិតនៅក្នុង ២១ ខេត្តផ្សេងគ្នា។

របាយការណ៍នោះ បានបង្ហាញឱ្យដឹងថា ចាប់តាំងពីឆ្នាំ ១៩៨៥ រហូតមកដល់ឆ្នាំ២០១១ នេះ ជនរងគ្រោះដោយសារទឹក អាស៊ីតមាន៣១៥នាក់ នៅទូទាំងប្រទេស កម្ពុជា ។ ខេត្តដែលកើតមានសកម្មភាពជះ ទឹកអាស៊ីតច្រើនជាងគេគឺខេត្តកំពង់ចាម និងរាជធានីភ្នំពេញ។ ជនរងគ្រោះក្រៅពី ស្ត្រី និងបុរសក្នុងនោះ មានកុមារស្ថិតនៅ ក្រោមអាយុ ១៣ ឆ្នាំ មាន ១០ភាគរយ។

លោកវេជ្ជបណ្ឌិត បូរ៉ា ជាមន្ត្រីនៃអង្គ ការជួយជនរងគ្រោះកម្ពុជាដោយសារទឹក អាស៊ីតបានប្រាប់មជ្ឈមណ្ឌលព័ត៌មានដើមអម្ពិលឱ្យដឹង នៅក្នុងឆ្នាំ២០១១នេះថា អង្គការរបស់លោកបានជួយសង្គ្រោះដោយព្យាបាលអ្នករងគ្រោះដោយសារទឹកអាស៊ីតមានចំនួន ១៥នាក់បានទទួលសេវាថ្នាំ និង ការព្យាបាលពិសេសការផ្តល់ការពិគ្រោះផងដែរ។

លោកបន្តថា ករណីជម្លោះដោយសារ យកទឹកអាស៊ីតមកជះកំហឹងនេះ កើតឡើង ដោយសារស្នេហាត្រីកោណគំនុំគុំគួនផ្សេងៗ ជាដើម។

លោកវេជ្ជបណ្ឌិតបានបញ្ជាក់ថា អង្គ ការសង្គមស៊ីវិលបានសាទរ ខណៈដែលរដ្ឋា ភិបាលបាន និងកំពុង ខិតខំប្រឹងប្រែងបង្កើត ឱ្យមានច្បាប់ស្តីពីការគ្រប់គ្រង ទឹកអាស៊ីត ធ្វើយ៉ាងណាក្នុងការដាក់ទោសទណ្ឌជនល្មើស និងការគ្រប់គ្រងទិញ-លក់ អាស៊ីតនៅ ប្រទេសកម្ពុជា។លោកថា សេចក្តីព្រាងច្បាប់ ស្តីពីការគ្រប់គ្រងដោយទឹកអាស៊ីតនេះមាន៥០មាត្រា តែបន្ទាប់ពីបញ្ជូនទៅទីស្តីការ គណៈរដ្ឋមន្ត្រី សេចក្តីព្រាងច្បាប់មួយនេះ ពិភាក្សាមកត្រឹម ២៦ មាត្រាវិញ។

ក្នុងនោះផងដែរ លោក អ៊ុក គឹមលេខ អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃធ្លាប់មានប្រសាសន៍ ប្រាប់មជ្ឈមណ្ឌលព័ត៌មានដើម អម្ពិលឱ្យដឹងថា រដ្ឋាភិបាលបាន និងកំពុង ប្រឹងប្រែងធ្វើយ៉ាងណា ឱ្យច្បាប់មួយនេះ លេចចេញជារូបរាងឡើង ។ ដែលបច្ចុប្បន្ន ច្បាប់មួយនេះកំពុងស្ថិតនៅក្រសួងមហាផ្ទៃដើម្បីធ្វើការពិនិត្យ និងពិភាក្សាជាបន្តទៀត និងឈានបញ្ជូនទៅទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងពេលខាងមុខនេះ។

សេចក្តីព្រាងច្បាប់ ស្តីពីការគ្រប់គ្រង ដោយទឹកអាស៊ីតមានសារសំខាន់ក្នុងសង្គមខ្មែរ នៅពេលដែលច្បាប់នេះចេញជាធរមាន ឡើងដើម្បីដាក់ទោសទណ្ឌជនល្មើស ព្រោះកន្លងមកគេយកក្រមព្រហ្មទណ្ឌក្នុងការជំនុំជម្រះករណីទឹកអាស៊ីត។ ម្យ៉ាងទៀតសោត ច្បាប់នេះនឹងធ្វើការគ្រប់គ្រងការជួញដូរទឹកអាស៊ីត ឱ្យមានច្បាប់ទិញ-លក់ត្រឹមត្រូវ៕

